# ជាតិមនុស្សអាក្រក់

១. ជាតិនុស្សអាក្រក់ ច្រើនសណ្ដាន អាក្រក់ប្រៀបបាន នឹងមេរោគ
ស៊ីជ្រៅហែកហួរ ខួរស្មោកគ្រោក សណ្ដានជាថោក អាក្រក់ក្រៃ ។

២. មនុស្សខ្លះអាក្រក់ ពីពូជពង្ស ព្រោះជាពូជល្ងង់ មិនស្គាល់ថ្លៃ
ស្គាល់តែទំលាប់ ថោករាល់ថ្ងៃ រស់ដោយបច្ច័យ នៃអាក្រក់ ។

៣. មនុស្សខ្លះអាក្រក់ ដោយវាចារ កូរទឹកដែលថ្លា អោយប្រែល្អក់
ព្រោះចិត្តតិរិឆ្ឆាន ដ៏កខ្វក់ ចាស់ថាអាក្រក់ ក្រៃកន្លង ។

៤. មនុស្សខ្លះអាក្រក់ ព្រោះបានផល ពីកម្មអកុសល្យ ដែលគេប៉ង
គេបានប្រព្រឹត្តិ គ្រាកន្លង ទើបពុំព្រមឆ្លង ទៅផ្លូវល្អ ។

៥. មនុស្សខ្លះអាក្រក់ ព្រោះវង្វេង មើលស្ដាំថាឆ្វេង ខ្មៅថាសរ
មើលមកក្រុមខ្លួន សុទ្ធតែល្អ ចាស់ថា គ្មានធមិ ប្រដៅឡើយ ។

៦. មនុស្សខ្លះអាក្រក់ អាងចេះដឹង រៀបរឹកក្បាលរឹង របៀបឈ្លើយ
អ្នកផ្សេងនែនាំ ធ្វើព្រងើយ ចាស់ថាកូនអើយ កុំរាប់ដល់ ។

៧. មនុស្សខ្លះអាក្រក់ ដោយកំហឹង ឆេះដោយមិនដឹង ហេតុដឹងផល
មិនពិចារណា រកកុសល្យ មនុស្សនេះដំកល់ តែចិត្តពាល ។

៨. មនុស្សខ្លះអាក្រក់ ដោយតណ្ហា ល្មោភស្រី ល្មោភស្រា ផឹកហាលវាល
ចាស់ថាមនុស្សនេះ សេពតែពាល លោកបានដំនៀល ថាមនុស្សថោក ។

៩. ជាតិមនុស្សអាក្រក់ ច្រើនសណ្ដាន ដែលខ្ញុំទើបបាន រៀបរាប់មក
គឺជាក្រុមនុស្ស ដ៏ស្មោកគ្រោក នាំសង្គមលោក អោយវិកវរ ។

១០. ជននេះគ្រោះថ្នាក់ ដល់សង្គម ព្រោះចង់ធ្វើធំ ច្រើនដំណេរ
មិនចាកអំណាច ដោយព្រះធម៌ ព្រោះខ្លាចកម្មល្អ តាមផ្តន្ទា ។

១១. ជននេះតែងរស់ ខ្លាចស្រមោល ដូចឆ្មារខ្លាចប៉ោល នាឡិការ
ទាំងពេល ដេក ដើ ស៊ី ធ្វើការ តែងចាញ់អាត្មា ខ្លាចខ្លួនឯង ។

១២. បើមាននណាហ៊ាន និយាយ បរិយាយអាក្រក់ រឿងជាក់ស្តែង
ក្រុមនេះមិនស្ងប់ ហើយរមែង រិះរករឿងផ្សេង មកធ្វើបាប ។

១៣. ក្រុមមនុស្សនេះជា ឈ្លើងសង្គម តែងប្រមូលផ្តុំ នូវទំលាប់
[ ចំណែន និន្ទា ឈ្នានីស ជាប់ ប្រព្រឹត្តិធ្វើបាប អ្នកទន់ខ្សោយ ។

១៤. ដូចនេះបើបាន ជួបឬស្គាល់ ចាស់ថាត្រូវខ្វល់ គិតមុខក្រោយ
ត្រូវចេះតតាំង កុំបណ្តោយ កុំបើកដៃអោយ គេជាន់ឈ្លី ។

១៥. សណ្តានអាក្រក់ នៃមនុស្សលោក ដែលរៀបរាប់មក គ្រាន់ជា ទី
បង្ហាញជាផ្លូវ ជនមូលមី កុំគិតសម្តី ថាគ្រប់គ្រាន់ ។

១៦. ត្រូវគិតពិចារ ដោយខ្លួនឯង មនុស្សខ្លះកើតស្រែង ដូចគីងគក់
ព្យាបាលមិនជា តែខំថ្លក់ អូសទាញស្រែកលក់ ថ្នាំស្រែងខ្លួន ។

ប្រទេស ម៉ាឡេស៊ី ថ្ងៃទី៩ ខែធ្នូរ ឆ្នាំ២០០៥

**សួន សេរីរដ្ឋា (ដែនដីសេរីភាព)**